សេចក្តីប្រកាសព័ត៌មានរួមរវាង

World Health Organization

## ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសុខភាពពិភពលោក

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៦

### ការកែតម្រូវសេចក្តីប្រកាសព័ត៌មាន៖ កម្ពុជាមិនមានករណីជំងឺហ្ស៊ីកានៅខេត្តកំពង់ចាមទេ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសកែតម្រូវលើសេចក្តីប្រកាសព័ត៌មានរបស់ក្រសួង ស្តីពីមានករណីជំងឺហ្ស៊ីកាដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចេញផ្សាយនៅវេលាម៉ោង៦ល្ងាចនៃថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦នេះ ដោយសូមជម្រាបជូនប្រជាជនកម្ពុជាទាំងអស់ឲ្យបានជ្រាបថា ក្រោយពីបានត្រួតពិនិត្យដោយហ្មត់ចត់លើលទ្ធផលមន្ទីរពិសោធន៍ដែលបានជូនព័ត៌មានពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាលើកទី១នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ រហូតមកដល់ម៉ោង ៧ ល្ងាចនៃថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (គឺប្រហែលជា ១ ម៉ោងក្រោយពីក្រសួងបានចេញសេចក្តីប្រកាសព័ត៌មានពីករណីវិជ្ជមានហ្ស៊ីកានៅខេត្តកំពង់ចាម) តាមរយៈការធ្វើវិភាគមន្ទីរពិសោធន៍តាមបែប Sequencing method ដើម្បីបញ្ជាក់ពីភាពវិជ្ជមានដែលបានឃើញនៅលើការវិភាគលើកទី១នោះ ក្រសួងសុខាភិបាលបានទទួលព័ត៌មានពីលទ្ធផលពិនិត្យបន្តលើកទី២ពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (តាមការធ្វើ molecular biology test ២ដង) ដោយមានការបញ្ជាក់ច្បាស់ថា ករណីដែលថាមានវិជ្ជមានវីរុសហ្ស៊ីកា លើបុរសម្នាក់អាយុ៤៤ឆ្នាំ នៅភូមិតាមាង ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាមនោះ គឺមិនត្រឹមត្រូវទេ ដោយជាលទ្ធផលចុងក្រោយ គឺ អវិជ្ជមានវីរុសហ្ស៊ីកា។

ដូច្នេះ បច្ចុប្បន្ននេះ ពុំមានករណីជំងឺហ្ស៊ីកាត្រូវបានរកឃើញមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នេះទេ។

ក្រសួងសុខាភិបាលនៅតែបន្តការយកចិត្តទុកដាក់តាមដានលើរាល់ករណីសង្ស័យហ្ស៊ីកា និងបន្តធ្វើការអប់រំប្រជាពលរដ្ឋកម្ពុជាទូទៅ ព្រមទាំងចាត់វិធានការនានានៅតាមតំបន់សង្ស័យ ដើម្បីកាត់ផ្តាច់ការចម្លងវីរុសហ្ស៊ីកាតាមរយៈមូសខ្លាខាំ ហើយឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមប្រកាសក្រើនរំលឹកដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ឲ្យបន្តចូលរួមទប់ស្កាត់កុំឲ្យមានការចម្លងវីរុសហ្ស៊ីកាចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុវត្តកិច្ចការពារដែលល្អបំផុតពីការចម្លងជំងឺហ្ស៊ីកា គឺត្រូវអនុវត្តកិច្ចការពារដូចនឹងការការពារជំងឺគ្រុនឈាម និងគ្រុនឈឹកដែរនោះ រួមមាន ការពារខ្លួនកុំឲ្យមូសខ្លាខាំ ស្ត្រីដែលមានផ្ទៃពោះឬមានផែនការនឹងមានផ្ទៃពោះនិងដៃគូរួមភេទរបស់គាត់រឹតតែត្រូវមានការប្រុងប្រយ័ត្នបន្ថែមទៀត ដើម្បីការពារខ្លួនពីមូសខ្លាដែលមានផ្ទុកវីរុសហ្ស៊ីកាខាំ និងការចម្លងតាមការរួមភេទ ហើយ ការការពារនេះ អាចអនុវត្តន៍បានដោយ៖

- បំបាត់ជម្រកមូសខ្លា ដោយធ្វើអនាម័យសំអាតជុំវិញផ្ទះ ការពារកុំឲ្យមានទឹកដក់នៅជុំវិញផ្ទះ លុបបំបាត់ថ្លុក សំបកកំប៉ុង សំបកកង់ឡាន ត្រឡោកដូង ធុងទឹក ជើងផ្កា និងប្រើអាបែតដាក់ក្នុងពាង ឬ អាងស្តុកទឹក។
- ស្លៀកពាក់ខោជើងវែង អាវដៃវែង និងស្រោមជើង ធ្វើយ៉ាងណាគ្របដណ្តប់ភាគច្រើននៃរាងកាយឲ្យជិត (សម្លៀកបំពាក់គួរតែមានពណ៌ភ្លឺ កុំខ្មៅឬងងឹត)
- ប្រើថ្នាំបាញ់ (spray) ឬលាប (repellent) កុំឲ្យមូសមកជិត ព្រោះថ្នាំនេះ ស្ត្រីមានផ្ទៃពោះអាចប្រើបាន ដោយមានសុវត្ថិភាព មិនមានផលប៉ះពាល់ទេ

- សំរាន្តក្នុងមុង គ្រប់ពេលសំរាន្តនៅពេលយប់និងថ្ងៃ ព្រមទាំងបើកបង្អួចឲ្យធំ ដើម្បីឲ្យពន្លឺថ្ងៃនិងខ្យល់ចេញចូលបានល្អ
- បើមិនចាំបាច់ *ស្ត្រីមានផ្ទៃពោះ គូស្វាមីភរិយាឬស្ត្រីមានគម្រោងមានផ្ទៃពោះ* ***មិនគួរឬមិនត្រូវ*** *ធ្វើដំណើរទៅកាន់តំបន់ដែលមានផ្ទុះ ឬកំពុងមានជំងឺហ្ស៊ីកា* ហើយត្រូវអនុវត្តន៍ការការពារខ្លួនដែលជំរាបជូនខាងនេះឲ្យបាន ខ្ជាប់ខ្ជួនបំផុត។
- បុរសនិងស្ត្រីដែលត្រឡប់មកពីតំបន់ដែលមានផ្ទុះឬកំពុងមានជំងឺហ្ស៊ីកា ត្រូវអនុវត្តការរួមភេទដែលមានសុវត្ថិភាព (ដោយប្រើប្រាស់ស្រោមអនាម័យ) ឬតមការរួមភេទយ៉ាងហោចណាស់៦ខែ បន្ទាប់ពីការវិលត្រឡប់មកវិញ ដើម្បីការពារការឆ្លងវីរុសហ្ស៊ីកាតាមការរួមភេទ ។
- គូស្វាមីភរិយា ឬស្ត្រីមានគម្រោងមានផ្ទៃពោះ ដែលទើបវិលត្រឡប់មកពីតំបន់ដែលផ្ទុះឬកំពុងមានជំងឺហ្ស៊ីកា ត្រូវរង់ចាំយ៉ាងតិច៦ខែមុនពេលព្យាយាមឲ្យមានផ្ទៃពោះដើម្បីធានាថា គ្មានការឆ្លងវីរុសហ្ស៊ីកាទៅទារកដែលនឹងបង្កកំណើត ។
- ដៃគូរួមភេទរបស់ស្ត្រី ដែលវិលត្រឡប់ពីតំបន់ដែលផ្ទុះឬកំពុងមានជំងឺហ្ស៊ីកា ត្រូវអនុវត្តការរួមភេទមានសុវត្ថិភាព (ប្រើស្រោមអនាម័យ)ឬជៀសវាងការរួមភេទក្នុងអំឡុងពេលមានផ្ទៃពោះ។
- ស្ត្រីដែលប្រើវិធីរួមភេទដោយមិនការពារ ប៉ុន្តែមិនចង់មានផ្ទៃពោះដោយសារតែការឆ្លងវីរុសហ្ស៊ីកា ត្រូវប្រើវិធីពន្យារកំណើតជាបន្ទាន់ ដោយអញ្ជើញមកពិគ្រោះជាមួយគ្រូពេទ្យជំនាញតាមមូលដ្ឋានសុខាភិបាលសាធារណៈ។
- ស្ត្រីមានផ្ទៃពោះដែលមានរោគសញ្ញានៃការឆ្លងវីរុសហ្ស៊ីកា ត្រូវតែពិនិត្យផ្ទៃពោះឲ្យបានញឹកញាប់ជាមួយគ្រូពេទ្យជំនាញ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ និងគ្រូពេទ្យដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ។

**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមថ្លែងនូវការកោតសរសើរដល់ការចូលរួមទប់ស្កាត់ការពារការចម្លងជំងឺហ្ស៊ីការបស់ប្រជាពលរដ្ឋទូទៅនិងមន្ត្រីសុខាភិបាលទាំងអស់ ដែលកំពុងសកម្មនៅក្នុងកិច្ចការពារនេះ ថ្វីត្បិតតែកម្ពុជាមិនទាន់រកឃើញមានករណីហ្ស៊ីកានៅពេលនេះក៏ដោយ ឯកឧត្តមរដ្ឋមន្ត្រី សូមក្រើនរំលឹកហើយរំលឹកទៀតជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសថា៖ សូមឲ្យប្រជាពលរដ្ឋយើង បន្តចូលរួម "*ទប់ស្កាត់និងការពារកុំឲ្យឆ្លងជំងឺហ្ស៊ីកា ដែលដូចទៅនឹងការការពារជំងឺគ្រុនឈាមនិងគ្រុនឈឹកដែរ ដោយអនុវត្តនូវវិធានការការពារកុំឲ្យមូសខ្លាខាំ តាមរយៈការកំចាត់ត្រពាំងដក់ទឹកដែលជាជំរកនៃការកកើតសត្វមូសខ្លា។ ខ្ញុំសូមអំពាវនាវ និងជំរុញឲ្យថ្នាក់ដឹកនាំមូលដ្ឋាន បន្តចលនាប្រជាជននៅក្នុងសហគមន៍ក្នុងការកំចាត់ជំរកដង្កូវទឹក ដែលនាំឲ្យមានមូសខ្លា ដែលជាភ្នាក់ងារបង្កជំងឺហ្ស៊ីកា និងជំងឺគ្រុនឈាម ព្រមទាំងស្លៀកពាក់ខោជើងវែងនិងអាវដៃវែង និងសំរាន្តក្នុងមុង។ ក្នុងករណីសង្ស័យ ឬពេលមានជំងឺដែលមានរោគសញ្ញាសង្ស័យ សូមអញ្ជើញទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ដែលនៅជិតលោកអ្នកបំផុត*"។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តរបស់ជំងឺនេះ តាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ។

សំរាប់ព័ត៌មានឬចម្ងល់បន្ថែមទៀតពាក់ព័ន្ធនឹងជំងឺឆ្លងខាងលើ សូមទាក់ទង៖

**ក្រសួងសុខាភិបាល**
នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
វេជ្ជបណ្ឌិត លី សុវ៉ាន់ ៖ ០១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**
វេជ្ជបណ្ឌិត រីគី ហ៊ូសៅ ៖ ០៩២ ៥៥៤ ១០០